# មិនដែលនៅតែឯងនោះទេ

តើមានអ្វីកើតឡើងប្រសិនបើអ៊ីសិន ឈឺម្តងទៀតនៅពេលគ្មាននរណាម្នាក់នៅទីនោះជួយ ?



ដោយ កាព្រីយ៉េល ស៊ុអ្វូហ្សារ៉ា
( ផ្អែកទៅលើដំណើររឿងពិត )
*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

អ៊ីសិន បានបុកជើងរបស់គាត់ជាមួយទោង ។ គាត់យោលទោងកាន់តែខ្ពស់ទៅៗ ។ ខ្យល់បក់ធ្វើឲ្យគាត់មានអារម្មណ៍ថាដូចជាគាត់កំពុងហោះ !

ហើយកណ្តឹងក៏បានរោទិ៍ឡើង ។ អ៊ីសិន បានដកដង្ហើមធំ ។ គាត់លេងមិនទាន់អស់ចិត្តទេ ។

ក្មេងៗបានតម្រង់ជួរដើម្បីត្រឡប់ទៅក្នុងថ្នាក់វិញ ។ អ៊ីសិន បន្ថយល្បឿនទោងរបស់គាត់ ។ បន្ទាប់មកគាត់បានចុះពីទោង ដើម្បីត្រឡប់ទៅថ្នាក់វិញ ។

ប៉ុន្តែពេលអ៊ីសិនដាក់ជើងដល់ដី គាត់មានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងនៅលើជើងរបស់គាត់ ។ គាត់បានដួលទៅលើដី ។ គាត់បានព្យាយាមក្រោកឈរ ប៉ុន្តែគាត់មានអារម្មណ៍ថាដូចភ្លើងកំពុងឆេះជើងគាត់ ។ វាឈឺចាប់ខ្លាំងណាស់ !

អ៊ីសិន ស្រែក « ជួយផង ! » ទាំងហូរទឹកភ្នែករហាម ។ កុមារៗ និងលោកគ្រូអ្នកគ្រូបានរត់ទៅជួយគាត់ ។

គ្រូម្នាក់បានសួរថា « តើមានបញ្ហាអ្វី ? »

« ខ្ញុំបាក់ជើងហើយ ! »

នេះមិនមែនជាលើកទីមួយ ដែលអ៊ីសិនបាក់ឆ្អឹងទេ ។ ហើយក៏មិនជាលើកទីពីរ ឬទីបីដែរ ! អ៊ីសិន មានជំងឺពុកឆ្អឹង ជាជំងឺម៉្យាងដែលធ្វើឲ្យឆ្អឹងងាយបាក់ ។ សូម្បីតែរឿងតូចតាច ដូចជាការឈានជើងឡើងលឿនបន្តិច ឬដើរបុកនរណាម្នាក់ ក៏អាចធ្វើឲ្យឆ្អឹងគាត់បាក់ដែរ ។

អ្នកគ្រូបាននិយាយថា « គ្រូនឹងទូរសព្ទទៅឪពុកម្តាយរបស់ប្អូនឲ្យនាំប្អូនទៅជួបគ្រូពេទ្យ » ។ « ហើយអ្វីៗគ្រប់យ៉ាងនឹងមិនអីទេ » ។

អ៊ីសិន សប្បាយចិត្តដែលមានមនុស្សនៅទីនោះដើម្បីជួយដល់គាត់ ។ ជើងរបស់គាត់នៅតែឈឺខ្លាំង ប៉ុន្តែគាត់បានដឹងថាគាត់នឹងមានសុវត្ថិភាព ។

ម៉ាក់ និងប៉ាបានទៅសាលារៀន ហើយបាននាំអ៊ីសិនទៅជួបគ្រូពេទ្យ ។ គ្រូពេទ្យបានរុំជើងគាត់ជាមួយនឹងស៊ីម៉ង់ពណ៌ខៀវ ហើយបានអនុញ្ញាតឲ្យទៅផ្ទះសម្រាក ។

ដោយសារជើងរបស់គាត់បាក់ អ៊ីសិន បានចំណាយពេលច្រើននៅលើគ្រែ ។ គាត់មានសៀវភៅជាច្រើនដើម្បីអាន ។ ពេលខ្លះមិត្តភក្តិរបស់គាត់បានមកលេងហ្គេមជាមួយគាត់ ។ ប៉ុន្តែគាត់នៅតែធុញថប់ ។

យប់មួយអ៊ីសិនភ្ញាក់ឡើង ហើយមិនអាចគេងលក់វិញទេ ។ គាត់ព្យាយាមបន្ធូរអារម្មណ៍ប៉ុន្តែគាត់នៅតែព្រួយបារម្ភ ។ *ចុះបើខ្ញុំបាក់ឆ្អឹង ហើយគ្មាននរណានៅជិតដូចជាឈឺទាំងកណ្តាលយប់វិញនោះ ?* អ៊ីសិនបានគិត ។ បេះដូងរបស់គាត់លោតញាប់ ។ គាត់មានអារម្មណ៍ភ័យខ្លាច ។

អ៊ីសិន បានស្រែក ។ « ប៉ា ! »

ប៉ាបានរត់ទៅបន្ទប់របស់អ៊ីសិន ។ « មានរឿងអីកូន ? »

អ៊ីសិន បាននិយាយថា « កូនខ្លាចណាស់ » ។ « ចុះបើកូនបាក់ឆ្អឹងមួយទៀត ហើយគ្មាននរណានៅទីនេះដើម្បីជួយកូនវិញនោះប៉ា ? »

ប៉ាបានអង្គុយក្បែរគាត់នៅលើគ្រែ ។ ប៉ាបានតបថា « នោះគឺជាគំនិតដ៏គួរឲ្យខ្លាច » ។ « ទោះបីជាយើងព្យាយាមប្រុងប្រយ័ត្ន និងរក្សាសុវត្ថិភាពក៏រឿងអាក្រក់នៅតែអាចកើតមានឡើងដែរកូន ។ ប៉ុន្តែមិនថាមានរឿងអ្វីកើតឡើងទេ ព្រះវរបិតាសួគ៌កំពុងតែថែរក្សាកូន » ។

អ៊ីសិនបាននិយាយថា « អ៊ីចឹងមានន័យថា ទ្រង់តែងតែនៅជាមួយកូនឬ ? »

« ត្រឹមត្រូវហើយកូន ! » ប៉ាបានឱបអ៊ីសិន ថ្នមៗ ។

អ៊ីសិនបានគិតអំពីការមកដល់របស់ប៉ាយ៉ាងលឿន ដើម្បីមកជួយគាត់ ។ គាត់ដឹងថាប៉ាស្រឡាញ់គាត់ ហើយតែងតែចង់ជួយគាត់ ។ ប្រហែលជាព្រះវរបិតាសួគ៌ក៏ដូច្នោះដែរ ។

នៅថ្ងៃបន្ទាប់ អ៊ីសិនបានអានព្រះគម្ពីរមួយនៅក្នុងទស្សនាវដ្តី *ប្រិយមិត្ត* ។ គម្ពីរបាននិយាយថា « ចូរសង្ឃឹមឡើង ហើយចូរកុំខ្លាចឡើយ ដ្បិតយើងជាព្រះអម្ចាស់ គង់នៅជាមួយនឹងអ្នក ហើយនឹងឈរនៅក្បែរអ្នក » ។*

អ៊ីសិន មានអារម្មណ៍ស្ងប់ស្ងាត់ និងមានសុវត្ថិភាពពេលគាត់អានព្រះគម្ពីរ គឺដូចអារម្មណ៍ដែលគាត់មានពេលនិយាយជាមួយប៉ារបស់គាត់ ។ គាត់បានដឹងថាព្រះវិញ្ញាណបរិសុទ្ធលួងលោមគាត់ ។ វាហាក់ដូចជាពេលគាត់បានឱបប៉ាម្តងទៀត ។

*អ៊ីសិនបានគិតថា,ខ្ញុំប្រហែលជានឹងបាក់ឆ្អឹងទៀត ប៉ុន្តែខ្ញុំមិនចាំបាច់ភ័យខ្លាចនោះទេ* ។ គាត់បានដឹងថា គាត់មិនដែលនៅតែឯងនោះទេ ។●

**គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨:៦ ។*



តើប្អូនមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះប្អូននៅពេលណា ?